៧-លោក ស៊ឹម សុផល	សប្បុរសជននៅក្រុងភ្នំពេញ	ទឹកប្រាក់ ចំនួន ១.៥០០ ដុល្លារ
៨-អ្នកស្រី កែច ម៉ន	សប្បុរសជនខ្មែរនៅសហរដ្ឋអាមេរិក	ទឹកប្រាក់ ចំនួន ១.៤០០ ដុល្លារ
៩-លោកជំទាវឃួរ សុខ	សប្បុរសជនខ្មែរនៅសហរដ្ឋអាមេរិក	ទឹកប្រាក់ ចំនួន ១.២៥០ ដុល្លារ
១០-អ្នកស្រី ឃ្លូក តាំង	សប្បុរសជនខ្មែរនៅសហរដ្ឋអាមេរិក	ទឹកប្រាក់ ចំនួន ១.២០០ ដុល្លារ
១១-លោក នួន ចន្ទ្រតារា	សប្បុរសជនខ្មែរនៅប្រទេសបារាំង	ទឹកប្រាក់ ចំនួន ១.០៥០ ដុល្លារ
១២-លោក ឃឹន រិទ្ធី	សប្បុរសជនខ្មែរនៅសហរដ្ឋអាមេរិក	ទឹកប្រាក់ ចំនួន ១.០០០ ដុល្លារ
១៣-លោក ហុង ម៉ោប	សប្បុរសជននៅខេត្តបាត់ដំបង	ទឹកប្រាក់ ចំនួន ១.០០០ ដុល្លារ
១៤-លោក មិត ឈើម	សប្បុរសជននៅខេត្តបាត់ដំបង	ទឹកប្រាក់ ចំនួន ១.០០០ ដុល្លារ

មាត្រា២.-

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី សហរដ្ឋមន្ត្រី ក្រសួង មហាផ្ទៃ និង អភិបាលខេត្តបាត់ដំបង ត្រូវអនុវត្ត អនុក្រឹត្យ នេះ អោយទទួលបានលទ្ធផលល្អ ។

រាជធានីភ្នំពេញ ថ្ងៃទី ២៤ ខែ មិថុនា ឆ្នាំ ២០០៤

នាយករដ្ឋមន្ត្រី

ហ៊ុន សែន

កន្លែងទទួល :

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចក្នុងមាត្រា១ និងមាត្រា២
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ: ៦៧៤៩ ...អនក្រ.តត

អនុក្រឹត្យ
ស្ដីពីការជូនមេដាយការងារ

រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្ដីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្ដីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្ដីពីការបង្កើត និង ប្រើប្រាស់គ្រឿងឥស្សរិយយស នៃ ព្រះរាជាណាចក្រកម្ពុជា
- តាមសំណើរបស់ គណៈកម្មការពិនិត្យលក្ខណសម្បត្តិវរជនដែលត្រូវជូនគ្រឿងឥស្សរិយយស

សម្រេច

មាត្រា១.-

ត្រូវបានបំពាក់ **មេដាយមាសការងារ** ចំនួន ០៣គ្រឿង ជូនទីប្រឹក្សាសម្ដេច ជា ស៊ីម ប្រធានព្រឹទ្ធសភា ចំនួន ០៣រូប ដែលមានស្នាដៃល្អ ក្នុងការបំពេញភារកិច្ច ជូនប្រទេសជាតិ ដូចមានរាយ នាមខាងក្រោមនេះ :-

១-ឯកឧត្ដម **ឆេព សារ៉ន**

២-ឯកឧត្ដម **ហាក់ ម៉ិនឃឿន**

៣-ឯកឧត្ដម **ម៉ៅ ធនិន**

មាត្រា២.-

រដ្ឋមន្ត្រីទទួលបន្ទុកទីស្ដីការគណៈរដ្ឋមន្ត្រី និង គណៈកម្មការពិនិត្យលក្ខណសម្បត្តិវរជនដែលត្រូវជូនគ្រឿងឥស្សរិយយស ត្រូវអនុវត្តអនុក្រឹត្យ នេះ អោយទទួលបានលទ្ធផលល្អ ។

រាជធានីភ្នំពេញ ថ្ងៃទី ១៨ ខែ មិថុនា ឆ្នាំ ២០០៤

នាយករដ្ឋមន្ត្រី

ហ៊ុន សែន

<u>កន្លែងទទួល</u> :
- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្ដេចនាយករដ្ឋមន្ត្រី
- ដូចក្នុងមាត្រា១ និងមាត្រា២
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា
លេខៈ ៣៥០ អនក្រ.តត

អនុក្រឹត្យ
ស្តីពីការតែងតាំងមន្ត្រីរាជការ

រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស / រកត / ១១៩៨ / ៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២ / នស / ៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស / រកម / ០១៩៦ / ១០ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការបង្កើតក្រសួងការបរទេស និង សហប្រតិបត្តិការអន្តរជាតិ
- បានឃើញព្រះរាជក្រឹត្យលេខ នស / រកត / ០៤០១ / ០៨៥ ចុះថ្ងៃទី ២៦ ខែ មេសា ឆ្នាំ ២០០១ ស្តីពីលក្ខន្តិកៈដោយឡែក នៃក្របខ័ណ្ឌមន្ត្រីការទូតជាន់ខ្ពស់
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងការបរទេស និង សហប្រតិបត្តិការអន្តរជាតិ

សម្រេច

មាត្រា១.-

តែងតាំងលោកជំទាវ **ហ៊ុន ស៊ីណាត** បច្ចុប្បន្ន អនុប្រធាននាយកដ្ឋានពិធីការ នៃក្រសួងការបរទេសនិងសហប្រតិបត្តិការអន្តរជាតិ ជាអគ្គកុងស៊ុលនៃព្រះរាជាណាចក្រកម្ពុជា ប្រចាំក្រុងគុងឈីង នៃសាធារណរដ្ឋប្រជាមានិតចិន ។

មាត្រា២.-

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងការបរទេសនិងសហប្រតិបត្តិការអន្តរជាតិ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋលេខាធិការនៃរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ សហរដ្ឋមន្ត្រី រដ្ឋមន្ត្រី រដ្ឋលេខាធិការ គ្រប់ក្រសួងស្ថាប័នដែលពាក់ព័ន្ធ និង សាមីខ្លួន ត្រូវអនុវត្តអនុក្រឹត្យនេះ អោយមានប្រសិទ្ធភាព ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី ២៣ ខែ មិថុនា ឆ្នាំ ២០០៤
នាយករដ្ឋមន្ត្រី

ហ៊ុន សែន

កន្លែងទទួល:
- *ក្រសួងព្រះបរមរាជវាំង*
- *អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា*
- *អគ្គលេខាធិការដ្ឋានរដ្ឋសភា*
- *អគ្គលេខាធិការរាជរដ្ឋាភិបាល*
- *ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី*
- *ដូចមាត្រា ២*
- *ឯកសារ-កាលប្បវត្តិ*

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ: ៣៥១ អនក្រ.តត

អនុក្រឹត្យ

ស្តីពីការតែងតាំងមន្ត្រីរាជការ

រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស / រកត / ១១៩៨ / ៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២ / នស / ៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស / រកម / ០១៩៦ / ១០ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការបង្កើតក្រសួងការបរទេស និង សហប្រតិបត្តិការអន្តរជាតិ
- បានឃើញព្រះរាជក្រឹត្យលេខ នស / រកត / ០៤០១ / ០៨៥ ចុះថ្ងៃទី ២៦ ខែ មេសា ឆ្នាំ ២០០១ ស្តីពីលក្ខន្តិកៈដោយឡែក នៃក្របខ័ណ្ឌមន្ត្រីការទូតជាន់ខ្ពស់
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងការបរទេស និង សហប្រតិបត្តិការអន្តរជាតិ

សម្រេច

មាត្រា១.-

តែងតាំងលោក **ជេត ណារ៉េន** បច្ចុប្បន្ន អគ្គនាយករង នៃអគ្គនាយកដ្ឋានអាស៊ាន នៃក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ ជាទីប្រឹក្សាស្ថានឯកអគ្គរាជទូតកម្ពុជាប្រចាំចក្រភពអង់គ្លេស ។

មាត្រា២.-

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងការបរទេសនិងសហប្រតិបត្តិការអន្តរជាតិ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋលេខាធិការនៃរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ សហរដ្ឋមន្ត្រី រដ្ឋមន្ត្រី រដ្ឋលេខាធិការ គ្រប់ក្រសួងស្ថាប័នដែលពាក់ព័ន្ធ និងសាមីខ្លួន ត្រូវអនុវត្តអនុក្រឹត្យនេះ អោយមានប្រសិទ្ធភាព ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី ២៣ ខែ មិថុនា ឆ្នាំ ២០០៤

នាយករដ្ឋមន្ត្រី

ហ៊ុន សែន

កន្លែងទទួល:

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចមាត្រា ២
- ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខៈ ៣៥៧ អនក្រ.បក

អនុក្រឹត្យ

ស្តីពីការបញ្ចប់អាណត្តិបេសកកម្មរបស់មន្ត្រីការទូត

៚៚៚៚

រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស / រកត / ១១៩៨ / ៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២ / នស / ៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស / រកម / ០១៩៦ / ១០ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការបង្កើតក្រសួងការបរទេស និង សហប្រតិបត្តិការអន្តរជាតិ
- បានឃើញព្រះរាជក្រឹត្យលេខ នស / រកត / ០៤០១ / ០៨៥ ចុះថ្ងៃទី ២៦ ខែ មេសា ឆ្នាំ ២០០១ ស្តីពីលក្ខន្តិកៈដោយឡែក នៃក្របខ័ណ្ឌមន្ត្រីការទូតជាន់ខ្ពស់
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងការបរទេស និង សហប្រតិបត្តិការអន្តរជាតិ

សម្រេច

មាត្រា១.-

ត្រូវបានផ្លាស់លោក **ហោ មុនីរ័ត្ន** បច្ចុប្បន្ន ទីប្រឹក្សាស្ថានឯកអគ្គរាជទូតកម្ពុជា ប្រចាំសាធារណរដ្ឋបារាំង អោយមកបំរើការងារក្នុងប្រទេសវិញ ដោយចប់អាណត្តិបេសកកម្ម។

មាត្រា២.-

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងការបរទេសនិងសហប្រតិបត្តិការអន្តរជាតិ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋលេខាធិការនៃរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ សហរដ្ឋមន្ត្រី រដ្ឋមន្ត្រី រដ្ឋលេខាធិការ គ្រប់ក្រសួងស្ថាប័នដែលពាក់ព័ន្ធ និង សាមីខ្លួន ត្រូវអនុវត្តអនុក្រឹត្យនេះ អោយមានប្រសិទ្ធភាព ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី ២៣ ខែ មិថុនា ឆ្នាំ ២០០៤

នាយករដ្ឋមន្ត្រី

ហ៊ុន សែន

កន្លែងទទួល:

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចមាត្រា ២
- ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា
លេខៈ ៣៥៣ អនក្រ.បក

អនុក្រឹត្យ

ស្តីពីការបញ្ចប់អាណត្តិបេសកកម្មរបស់មន្ត្រីការទូត

រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស / រកត / ១១៩៨ / ៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២ / នស / ៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស / រកម / ០១៩៦ / ១០ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការបង្កើតក្រសួងការបរទេស និង សហប្រតិបត្តិការអន្តរជាតិ
- បានឃើញព្រះរាជក្រឹត្យលេខ នស / រកត / ០៤០១ / ០៨៥ ចុះថ្ងៃទី ២៦ ខែ មេសា ឆ្នាំ ២០០១ ស្តីពីលក្ខន្តិកៈដោយឡែក នៃក្របខ័ណ្ឌមន្ត្រីការទូតជាន់ខ្ពស់
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងការបរទេស និង សហប្រតិបត្តិការអន្តរជាតិ

សម្រេច

មាត្រា១.-

ត្រូវបានផ្លាស់លោក ហ៊ុយ សារ៉ាវុធ បច្ចុប្បន្នទីប្រឹក្សាស្ថានឯកអគ្គរាជទូតកម្ពុជា ប្រចាំសាធារណរដ្ឋបារាំង អោយមកបំរើការងារក្នុងប្រទេសវិញ ដោយចប់អាណត្តិបេសកកម្ម។

មាត្រា២.-

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងការបរទេសនិងសហប្រតិបត្តិការអន្តរជាតិ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋលេខាធិការនៃរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ សហរដ្ឋមន្ត្រី រដ្ឋមន្ត្រី រដ្ឋលេខាធិការ គ្រប់ក្រសួងស្ថាប័នដែលពាក់ព័ន្ធនិង សាមីខ្លួន ត្រូវអនុវត្តអនុក្រឹត្យនេះ អោយមានប្រសិទ្ធភាព ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ .

រាជធានីភ្នំពេញ ថ្ងៃទី ២៣ ខែ មិថុនា ឆ្នាំ ២០០៤

នាយករដ្ឋមន្ត្រី

ហ៊ុន សែន

កន្លែងទទួលៈ
- *ក្រសួងព្រះបរមរាជវាំង*
- *អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា*
- *អគ្គលេខាធិការដ្ឋានរដ្ឋសភា*
- *អគ្គលេខាធិការរាជរដ្ឋាភិបាល*
- *ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី*
- *ដូចមាត្រា ២*
- *ឯកសារ-កាលប្បវត្តិ*

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ: ៣៥៤ អនក្រ.តត

អនុក្រឹត្យ

ស្តីពីការតែងតាំងមន្ត្រីរាជការ

រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស / រកត / ១១៩៨ / ៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២ / នស / ៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស / រកម / ០១៩៦ / ១០ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការបង្កើតក្រសួងការបរទេស និង សហប្រតិបត្តិការអន្តរជាតិ
- បានឃើញព្រះរាជក្រឹត្យលេខ នស / រកត / ០៤០១ / ០៨៥ ចុះថ្ងៃទី ២៦ ខែ មេសា ឆ្នាំ ២០០១ ស្តីពីលក្ខន្តិកៈដោយឡែក នៃក្របខ័ណ្ឌមន្ត្រីការទូតជាន់ខ្ពស់
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងការបរទេស និង សហប្រតិបត្តិការអន្តរជាតិ

សម្រេច

មាត្រា១.-

តែងតាំងលោកស្រី **ផាន់ ឡូទី** បច្ចុប្បន្ន អនុប្រធាននាយកដ្ឋានអង្គការហ្វ្រង់កូហ្វូនី នៃក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ ជាទីប្រឹក្សាស្ថានឯកអគ្គរាជទូតកម្ពុជា ប្រចាំ សាធារណរដ្ឋបារាំង ។

មាត្រា២.-

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងការបរទេសនិងសហប្រតិបត្តិការអន្តរជាតិ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋលេខាធិការនៃរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ សហរដ្ឋមន្ត្រី រដ្ឋមន្ត្រី រដ្ឋលេខាធិការ គ្រប់ក្រសួងស្ថាប័នដែលពាក់ព័ន្ធ និង សាមីខ្លួន ត្រូវអនុវត្តអនុក្រឹត្យនេះ អោយមានប្រសិទ្ធភាព ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី ២៣ ខែ មិថុនា ឆ្នាំ ២០០៤

នាយករដ្ឋមន្ត្រី

ហ៊ុន សែន

កន្លែងទទួល:

- *ក្រសួងព្រះបរមរាជវាំង*
- *អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា*
- *អគ្គលេខាធិការដ្ឋានរដ្ឋសភា*
- *អគ្គលេខាធិការរាជរដ្ឋាភិបាល*
- *ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី*
- *ដូចមាត្រា ២*
- *ឯកសារ-កាលប្បវត្តិ*

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា
លេខ: ៣៥៥ អនក្រ.តត

អនុក្រឹត្យ
ស្តីពីការតែងតាំងមន្ត្រីរាជការ

រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស / រកត / ១១៩៨ / ៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២ / នស / ៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស / រកម / ០១៩៦ / ១០ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការបង្កើតក្រសួងការបរទេស និង សហប្រតិបត្តិការអន្តរជាតិ
- បានឃើញព្រះរាជក្រឹត្យលេខ នស / រកត / ០៤០១ / ០៨៥ ចុះថ្ងៃទី ២៦ ខែ មេសា ឆ្នាំ ២០០១ ស្តីពីលក្ខន្តិកៈដោយឡែក នៃក្របខ័ណ្ឌមន្ត្រីការទូតជាន់ខ្ពស់
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងការបរទេស និង សហប្រតិបត្តិការអន្តរជាតិ

សម្រេច

មាត្រា១ .-

តែងតាំងកញ្ញា **ឆាន ឫទ្ធិម** បច្ចុប្បន្នអនុប្រធាននាយកដ្ឋានអាស៊ី១ នៃក្រសួងការបរទេសនិងសហប្រតិបត្តិការអន្តរជាតិ ជាទីប្រឹក្សាស្ថានឯកអគ្គរាជទូតកម្ពុជា ប្រចាំប្រទេសជប៉ុន ។

មាត្រា២ .-

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងការបរទេសនិងសហប្រតិបត្តិការអន្តរជាតិ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋលេខាធិការនៃរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ សហរដ្ឋមន្ត្រី រដ្ឋមន្ត្រី រដ្ឋលេខាធិការ គ្រប់ក្រសួងស្ថាប័នដែលពាក់ព័ន្ធ និងសាមីខ្លួន ត្រូវអនុវត្តអនុក្រឹត្យនេះអោយមានប្រសិទ្ធភាព ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី ២៣ ខែ មិថុនា ឆ្នាំ ២០០៤

នាយករដ្ឋមន្ត្រី

ហ៊ុន សែន

កន្លែងទទួល:
- *ក្រសួងព្រះបរមរាជវាំង*
- *អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា*
- *អគ្គលេខាធិការដ្ឋានរដ្ឋសភា*
- *អគ្គលេខាធិការរាជរដ្ឋាភិបាល*
- *ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី*
- *ដូចមាត្រា ២*
- *ឯកសារ-កាលប្បវត្តិ*

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ: ៣៥៦ អនក្រ.បក

អនុក្រឹត្យ

ស្តីពីការបញ្ចប់អាណត្តិបេសកកម្មរបស់មន្ត្រីការទូត

រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស / រកត / ១១៩៨ / ៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២ / នស / ៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស / រកម / ០១៩៦ / ១០ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការបង្កើតក្រសួងការបរទេស និង សហប្រតិបត្តិការអន្តរជាតិ
- បានឃើញព្រះរាជក្រឹត្យលេខ នស / រកត / ០៤០១ / ០៨៥ ចុះថ្ងៃទី ២៦ ខែ មេសា ឆ្នាំ ២០០១ ស្តីពីលក្ខន្តិកៈដោយឡែក នៃក្របខ័ណ្ឌមន្ត្រីការទូតជាន់ខ្ពស់
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងការបរទេស និង សហប្រតិបត្តិការអន្តរជាតិ

សម្រេច

មាត្រា១ .-

ត្រូវបានផ្លាស់លោក **អោក ថេន** បច្ចុប្បន្នអគ្គទីប្រឹក្សាស្ថានឯកអគ្គរាជទូតកម្ពុជា ប្រចាំប្រទេសជប៉ុន អោយមកបំរើការងារក្នុងប្រទេសវិញ ដោយចប់អាណត្តិបេសកកម្ម ។

មាត្រា២ .-

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងការបរទេសនិងសហប្រតិបត្តិការអន្តរជាតិ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋលេខាធិការនៃរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ សហរដ្ឋមន្ត្រី រដ្ឋមន្ត្រី រដ្ឋលេខាធិការ គ្រប់ក្រសួងស្ថាប័នដែលពាក់ព័ន្ធ និងសាមីខ្លួន ត្រូវអនុវត្តអនុក្រឹត្យនេះអោយមានប្រសិទ្ធភាព ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី ២៣ ខែ មិថុនា ឆ្នាំ ២០០៤

នាយករដ្ឋមន្ត្រី

ហ៊ុន សែន

កន្លែងទទួល:

- *ក្រសួងព្រះបរមរាជវាំង*
- *អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា*
- *អគ្គលេខាធិការដ្ឋានរដ្ឋសភា*
- *អគ្គលេខាធិការរាជរដ្ឋាភិបាល*
- *ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី*
- *ដូចមាត្រា ២*
- *ឯកសារ-កាលប្បវត្តិ*

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា
លេខ: ៣៥៧ អនក្រ.តត

អនុក្រឹត្យ

ស្តីពីការបញ្ចប់អាណត្តិបេសកកម្មរបស់មន្ត្រីការទូត

៚៚៚៚

រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស / រកត / ១១៩៨ / ៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២ / នស / ៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស / រកម / ០១៩៦ / ១០ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការបង្កើតក្រសួងការបរទេស និង សហប្រតិបត្តិការអន្តរជាតិ
- បានឃើញព្រះរាជក្រឹត្យលេខ នស / រកត / ០៤០១ / ០៨៥ ចុះថ្ងៃទី ២៦ ខែ មេសា ឆ្នាំ ២០០១ ស្តីពីលក្ខន្តិកៈដោយឡែក នៃក្របខ័ណ្ឌមន្ត្រីការទូតជាន់ខ្ពស់
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងការបរទេស និង សហប្រតិបត្តិការអន្តរជាតិ

សម្រេច

មាត្រា១ .-

ត្រូវបានផ្លាស់លោក ហើស សិរីធន បច្ចុប្បន្នទីប្រឹក្សាស្ថានឯកអគ្គរាជទូតកម្ពុជា ប្រចាំសាធារណរដ្ឋឥណ្ឌា អោយមកបំរើការងារក្នុងប្រទេសវិញ ដោយចប់អាណត្តិបេសកកម្ម។

មាត្រា២ .-

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងការបរទេសនិងសហប្រតិបត្តិការអន្តរជាតិ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋលេខាធិការនៃរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ សហរដ្ឋមន្ត្រី រដ្ឋមន្ត្រី រដ្ឋលេខាធិការ គ្រប់ក្រសួងស្ថាប័នដែលពាក់ព័ន្ធ និងសាមីខ្លួន ត្រូវអនុវត្តអនុក្រឹត្យនេះ អោយមានប្រសិទ្ធភាព ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី ៧ ខែ មិថុនា ឆ្នាំ ២០០៤

នាយករដ្ឋមន្ត្រី

ហ៊ុន សែន

កន្លែងទទួល:
- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចមាត្រា ២
- ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ: ៣៥៧ អនក្រ.បក

អនុក្រឹត្យ
ស្តីពីការជូនមេដាយមុនីសារាភ័ណ្ឌ

រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពី ការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៩ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពី ការបង្កើត និង ប្រើប្រាស់គ្រឿងឥស្សរិយយស នៃ ព្រះរាជាណាចក្រកម្ពុជា
- តាមសំណើរបស់ រដ្ឋមន្ត្រី ក្រសួងធម្មការ និង សាសនា

សម្រេច

មាត្រា១. -

ត្រូវបានបំពាក់ **មេដាយមុនីសារាភ័ណ្ឌ** ថ្នាក់ **សេនា** ប្រគេន ព្រះតេជគុណ **ទឹម មុន្នី** ដែលបានខិតខំប្រឹងប្រែងអំពាវនាវ ពុទ្ធបរិស័ទ និង បានបរិច្ចាគបច្ច័យផ្ទាល់ព្រះអង្គ ចំនួន ១៤២.៤៥៨ ដុល្លារ ដើម្បីចូលរួមជួយកសាងសមិទ្ធផលនានា យ៉ាងច្រើន នៅក្នុងវត្ត និរោធរង្សី សង្កាត់និរោធ ខណ្ឌមានជ័យ រាជធានីភ្នំពេញ ។

មាត្រា២. -

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រី ក្រសួងធម្មការ និង សាសនា និង អភិបាលរាជធានីភ្នំពេញ ត្រូវអនុវត្ត អនុក្រឹត្យ នេះ អោយទទួលបានលទ្ធផលល្អ ។

រាជធានីភ្នំពេញ ថ្ងៃទី ២១ ខែ មិថុនា ឆ្នាំ ២០០៤

នាយករដ្ឋមន្ត្រី

ហ៊ុន សែន

កន្លែងទទួល :
- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចក្នុងមាត្រា១ និងមាត្រា២
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខៈ ៣៤៤ អនក្រ.បក

អនុក្រឹត្យ
ស្តីពីការជូនមេដាយស្ថាបនាជាតិ

រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើត និង ប្រើប្រាស់គ្រឿងឥស្សរិយយស នៃ ព្រះរាជាណាចក្រកម្ពុជា

-តាមសំណើរបស់ រដ្ឋមន្ត្រី ក្រសួងធម្មការ និង សាសនា

សម្រេច

មាត្រា១. ~

ត្រូវបានបំពាក់ **មេដាយមាសស្ថាបនាជាតិ** ជូនសប្បុរសជននៅប្រទេសបារាំង ចំនួន ០៩ រូប ដែលបានបរិច្ចាគថវិកាចូលរួមជួយកសាងសមិទ្ធផលនានាយ៉ាងច្រើន នៅក្នុងវត្ត និរោធរង្សី សង្កាត់និរោធ ខណ្ឌមានជ័យ រាជធានីភ្នំពេញ ដូចមានរាយនាមខាងក្រោមនេះ :-

១-លោកស្រី **ឧត្តរ៉ា** ហៅ **ពិន រី**	ថវិកាចំនួន ១១.៥០០ ដុល្លារ
២-លោក **ហេង គិន**	ថវិកាចំនួន ១០.៥០០ ដុល្លារ
៣-លោកស្រី តេ **ចន្ទនីគីមសាន**	ថវិកាចំនួន ១០.៤០០ ដុល្លារ
៤-លោកស្រី **ឡូ ហុង**	ថវិកាចំនួន ១០.៥០០ ដុល្លារ
៥-លោកស្រី **ស៊ាយ ម៉ូគីន**	ថវិកាចំនួន ១០.០៥០ ដុល្លារ
៦-លោកស្រី **ស៊ាំង ឆេងហៀក**	ថវិកាចំនួន ១០.៥០០ ដុល្លារ
៧-លោក **គិន គីរី**	ថវិកាចំនួន ១០.២៥០ ដុល្លារ
៨-លោកស្រី តេ **បុប្ផា** ហៅ **ណារ៉ាណារី**	ថវិកាចំនួន ១០.៥០០ ដុល្លារ
៩-លោកស្រី តេ **គឹមអេង**	ថវិកាចំនួន ១០.០៦០ ដុល្លារ

មាត្រា២. ~

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រី ក្រសួងធម្មការ និង សាសនា និង អភិបាលរាជធានីភ្នំពេញ ត្រូវអនុវត្ត អនុក្រឹត្យ នេះ អោយទទួលបានលទ្ធផលល្អ ។

រាជធានីភ្នំពេញ ថ្ងៃទី ២១ ខែ មិថុនា ឆ្នាំ ២០០៤

នាយករដ្ឋមន្ត្រី

ហ៊ុន សែន

កន្លែងទទួល :

-ក្រសួងព្រះបរមរាជវាំង
-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
-អគ្គលេខាធិការដ្ឋានរដ្ឋសភា
-អគ្គលេខាធិការរាជរដ្ឋាភិបាល
-ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
-ដូចក្នុងមាត្រា១ និងមាត្រា២
-រាជកិច្ច
-ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ: ៣៦០.អនក្រ.បក

អនុក្រឹត្យ
ស្តីពីការជូនមេដាយស្ថាបនាជាតិ

រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពី ការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាស អោយប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពី ការបង្កើត និង ប្រើប្រាស់គ្រឿងឥស្សរិយយស នៃ ព្រះរាជាណាចក្រកម្ពុជា

-តាមសំណើរបស់ រដ្ឋមន្ត្រី ក្រសួងធម្មការ និង សាសនា

សម្រេច

មាត្រា១. ~

ត្រូវបានបំពាក់ **មេដាយមាសស្ថាបនាជាតិ** ចំនួន ០២គ្រឿង ប្រគេន និង ជូនសប្បុរសជន ចំនួន០២រូប ដែលបានបរិច្ចាគបច្ច័យ និង ថវិកា ចូលរួមជួយកសាង សមិទ្ធផល នៅក្នុងវត្តអង្គតាព្រះ ឃុំមហាឫស្សី ស្រុកគងពិសី ខេត្តកំពង់ស្ពឺ ដូចមានរាយព្រះនាម និង នាមខាងក្រោមនេះ :-

១-ព្រះតេជគុណ **ម៉ែន ស៊ឹម** ព្រះចៅអធិការវត្តអង្គតាព្រះ ជួយកសាងព្រះវិហារ សាលាឆាន់ និង សមិទ្ធផលផ្សេងៗទៀត ចំណាយអស់បច្ច័យ ចំនួន ១១.៥៨០ ដុល្លារ ។

២-លោកតា **យូ ទឹម** សប្បុរសជន នៅសហរដ្ឋអាមេរិក ជួយកសាង សាលាធម្មសភា កុដិឈើ និង សមិទ្ធផលផ្សេងៗទៀត ចំណាយអស់ថវិកា ចំនួន ១១.៥០០ ដុល្លារ ។

មាត្រា២. ~

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រី ក្រសួងធម្មការ និង សាសនា និង អភិបាលខេត្តកំពង់ស្ពឺ ត្រូវ អនុវត្តអនុក្រឹត្យ នេះអោយទទួលបានលទ្ធផលល្អ ។

រាជធានីភ្នំពេញ, ថ្ងៃទី [illegible] ខែ មិថុនា ឆ្នាំ ២០០៤

នាយករដ្ឋមន្ត្រី

ហ៊ុន សែន

កន្លែងទទួល :

-ក្រសួងព្រះបរមរាជវាំង
-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
-អគ្គលេខាធិការដ្ឋានរដ្ឋសភា
-អគ្គលេខាធិការ រាជរដ្ឋាភិបាល
-ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
-ដូចក្នុងមាត្រា១ និងមាត្រា២
-រាជកិច្ច
-ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ: ៧៦១ អនក្រ.តត

អនុក្រឹត្យ
ស្តីពីការជូនមេដាយស្ថាបនាជាតិ

រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើត និង ប្រើប្រាស់គ្រឿងឥស្សរិយយស នៃ ព្រះរាជាណាចក្រកម្ពុជា
- តាមសំណើរបស់ អភិបាល ខេត្តបាត់ដំបង

សម្រេច

មាត្រា១.

ត្រូវបានបំពាក់ **មេដាយមាសស្ថាបនាជាតិ** ជូនសប្បុរសជន ចំនួន ០៣ រូប ដែលបានបរិច្ចាគទ្រព្យធនផ្ទាល់ខ្លួនចូលរួមជួយកសាងសមិទ្ធផលនានា ជាប្រយោជន៍ដល់សង្គមជាតិ នៅក្នុងស្រុកកំរៀង និង ស្រុកថ្មគោល ខេត្តបាត់ដំបង ដូចមានរាយនាម ខាងក្រោមនេះ :-

១-លោក **គ្រាប ឌុយឌេន** សប្បុរសជននៅស្រុកថ្មគោល បានជួយកសាងអគារពុទ្ធិកៈបឋមសិក្សា ០១ខ្នង ពីរជាន់ នៅវត្តនិគម និង ជួសជុលផ្លូវចូលភូមិ នៅក្នុងភូមិនិគម ឃុំជ្រោយស្តៅ ស្រុកថ្មគោល ចំណាយអស់ទឹកប្រាក់ ចំនួន ១៩.៦២០ ដុល្លារ ។

២-លោក **នី មុត** សប្បុរសជន នៅសហរដ្ឋអាមេរិក បានជួយកសាងសាលាឆទាន នៅភូមិទួលថ្នាន់ វត្តតាក្រី និង ព្រះវិហារ វត្តសំរោង ស្រុកកំរៀង ចំណាយអស់ទឹកប្រាក់ ចំនួន ១០.៨៣០ ដុល្លារ ។

៣-លោក **សៅ ស៊ុំ** សប្បុរសជន នៅសហរដ្ឋអាមេរិក បានជួយកសាងព្រះវិហារ វត្តព្រះពន្លា ឃុំរូងជ្រៃ ស្រុកថ្មគោល ចំណាយអស់ទឹកប្រាក់ ចំនួន ១៨.៤០០ ដុល្លារ ។

មាត្រា២.

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី សហរដ្ឋមន្ត្រី ក្រសួងមហាផ្ទៃ និង អភិបាលខេត្តបាត់ដំបង ត្រូវអនុវត្តអនុក្រឹត្យ នេះ អោយទទួលបានលទ្ធផលល្អ ។

រាជធានីភ្នំពេញ ថ្ងៃទី ២៧ ខែ មិថុនា ឆ្នាំ ២០០៤

នាយករដ្ឋមន្ត្រី

ហ៊ុន សែន

<u>កន្លែងទទួល</u> :
- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចក្នុងមាត្រា១ និងមាត្រា២
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

213

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ : ៣៧. សសរ

សេចក្តីសម្រេច

ស្តីពីការបង្កើតឡើងនូវក្រុមការងារចំរុះមួយ

រវាងអាជ្ញាធរប្រេងកាតជាតិកម្ពុជា ជាមួយនឹង

ក្រុមហ៊ុន Chevron Overseas Petroleum Limited ព្រមទាំងក្រុមហ៊ុនដៃគូ និងស្ថាប័នពាក់ព័ន្ធ

ដើម្បីសិក្សារួមគ្នារៀបចំអោយមានការអភិវឌ្ឍន៍ហេដ្ឋារចនាសម្ព័ន្ធគាំទ្រដល់ការប្រើប្រាស់

ឧស្ម័នធម្មជាតិ ពីប្លុក A ដែនសមុទ្រកម្ពុជា

រាជរដ្ឋាភិបាលកម្ពុជា

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញ ព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ១៩៩៨ ស្តីពីការតែងតាំង រាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញ ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/០១៩៨/០២០ ចុះថ្ងៃទី២២ ខែមករា ឆ្នាំ១៩៩៨ ស្តីពីការបង្កើត អាជ្ញាធរប្រេងកាតជាតិកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស /រកម /០១៩៦ /០៩ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ស្តីពី ការបង្កើតទីស្តីការគណៈរដ្ឋមន្ត្រី
- តាមសំណើរបស់ទេសរដ្ឋមន្ត្រី និង ជាប្រធានអាជ្ញាធរប្រេងកាតជាតិកម្ពុជា

សម្រេច

ប្រការ ១ : បង្កើតក្រុមការងារចំរុះមួយទទួលបន្ទុកអនុវត្តន៍កិច្ចព្រមព្រៀងសិក្សារួមគ្នា ដើម្បីរៀបចំអោយមានកាលានុវត្តន៍ភាពចំពោះការអភិវឌ្ឍន៍ហេដ្ឋារចនាសម្ព័ន្ធគាំទ្រដល់ការវិនិយោគទុន នៃឧស្ម័នធម្មជាតិនៅក្នុង ព្រះរាជាណាចក្រកម្ពុជា ដែលមានសមាសភាពដូចខាងក្រោម :

១-ឯកឧត្តម **សុខ អាន,** ទេសរដ្ឋមន្ត្រី និង រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី ប្រធានក្រុមការងារ និង អ្នកធានា (Chairman and Sponsor)

២-ឯកឧត្តម សុខ ចិន្តា, តំណាងក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា សមាជិក

៣-ឯកឧត្តម ញឹក ច្រិង, តំណាងក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល សមាជិក

៤-ឯកឧត្តម ទី នរិន្ទ, តំណាងអាជ្ញាធរអគ្គីសនីកម្ពុជា សមាជិក

៥-ឯកឧត្តម តែ ដួង តារា, តំណាងអាជ្ញាធរប្រេងកាតជាតិកម្ពុជា សមាជិក

៦-ឯកឧត្តម សយ សុខា, តំណាងទីស្តីការគណៈរដ្ឋមន្ត្រី សមាជិក

៧-លោក យឹម ណុលសុន, តំណាងអគ្គីសនីកម្ពុជា សមាជិក

៨-លោក វ៉ាន់ ហុង, មន្ត្រីអាជ្ញាធរប្រេងកាតជាតិកម្ពុជា លេខាធិការក្រុមការងារ

ប្រការ ២ : ក្រុមការងារចំរុះនេះមានភារកិច្ច ធ្វើការជាមួយគ្នានឹងក្រុមការងារនៃក្រុមហ៊ុនរុករកប្រេងកាតអាមេរិកាំង **Chevron Overseas Petroleum Limited** ព្រមទាំងក្រុមហ៊ុនដៃគូ និងស្ថាប័នពាក់ព័ន្ធ ដើម្បី :

- រៀបចំផ្តល់អនុសាសន៍សេដ្ឋកិច្ចលំអិតមួយជូនរាជរដ្ឋាភិបាលស្តីពី វិធី មធ្យោបាយ និងជំរើស ដែលទាក់ទងដល់ការអភិវឌ្ឍន៍ហេដ្ឋារចនាសម្ព័ន្ធគាំទ្រដល់ការប្រើប្រាស់ឧស្ម័នធម្មជាតិពីប្លុក A ដែនសមុទ្រកម្ពុជា បំរើអោយរោងចក្រ អគ្គិសនី និង អាជីវកម្ម ឧស្សាហកម្មដទៃទៀត នៅក្នុងព្រះរាជាណាចក្រកម្ពុជា ។
- រៀបចំផែនការជំហានដំបូង សំរាប់ការអនុវត្តន៍ នៃគ្រប់គំរោងការថាមពលទាំងអស់ ដែលនឹងប្រើប្រាស់ឧស្ម័នធម្មជាតិជាវត្ថុធាតុដើម និងគ្រប់គំរោងការងារហេដ្ឋារចនាសម្ព័ន្ធនានាដែលពាក់ព័ន្ធ ។
- ធ្វើការពិនិត្យដោយហ្មត់ចត់សារឡើងវិញនូវបទដ្ឋាន បទបញ្ញត្តិ ក្របខ័ណ្ឌច្បាប់ ដោយសំរបសំរួលជាមួយអ្វីដែលមាននៅនឹងកន្លែង និងតំរូវថ្មីចាំបាច់ ដើម្បីគ្រប់គ្រង និងជំរុញលើកទឹកចិត្តដល់ការវិនិយោគទុន និងអាជីវកម្មកិតអាប់ស្រ្ទីម មីតស្រ្ទីម និង ដោនស្រ្ទីមគាំទ្រដល់ការប្រើប្រាស់ឧស្ម័នធម្មជាតិ ។
- ផ្តល់អនុសាសន៍លើការកំណត់ដាក់ចេញ នូវសេចក្តីសំរេច អាជ្ញាប័ណ្ណផ្លូវការ (រួមបញ្ចូលទាំងអាជ្ញាប័ណ្ណបរិស្ថានផង) និងការយល់ព្រមដែលតំរូវចាំបាច់អោយមាន ក្នុងការអនុវត្តន៍ចំពោះគ្រប់គំរោងការថាមពលទាំងឡាយ ហើយនិងបង្ហាញជូននាកាលវេលាសមស្របនូវបណ្តាបញ្ហាដែលអាចកើតមានឡើង ក្នុងការអនុវត្តន៍គំរោង និងដំណោះស្រាយចំពោះបញ្ហាទាំងនោះផង ។
- ធ្វើរបាយការណ៍អំពីលទ្ធផល នៃការសិក្សារួមគ្នា ជូនរាជរដ្ឋាភិបាលទៅតាមជំហានការងារនីមួយៗ ។

ប្រការ ៣ : ប្រធានក្រុមការងារមានសិទ្ធិជ្រើសតាំងបន្ថែមនូវសមាជិកក្រុមការងារថ្មី ទៅតាមតំរូវការចាំបាច់ ។ ក្នុងពេលកោះប្រជុំការងារ ប្រធានក្រុមការងារមានសិទ្ធិ អញ្ជើញចូលរួមក្រុមការងារក្រុមហ៊ុន Chevron Overseas Petroleum (Cambodia) Limited និងតំណាងក្រុមហ៊ុនដៃគូរក្នុងគំរោងការងារ និងតំណាងក្រុមហ៊ុនរដ្ឋ ឯកជនដទៃទៀត ដែលពាក់ព័ន្ធក្នុងការសិក្សារួមគ្នានេះ ។

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា
លេខៈ ០៧ បប

បទបញ្ជា
ស្ដីពី
ការទប់ស្កាត់ និងលុបបំបាត់អំពើអនាធិបតេយ្យ នៅតំបន់រមណីយដ្ឋានអង្គរ ខេត្តសៀមរាប

កន្លងមក រាជរដ្ឋាភិបាលបានចេញសារាចរលេខ ០១ សរ ចុះថ្ងៃទី ០៦ ខែ ឧសភា ឆ្នាំ ២០០៣ ស្ដីពីការទប់ស្កាត់អំពើអនាធិបតេយ្យនៅតំបន់សៀមរាប-អង្គរ ដោយបានធ្វើការផ្សព្វផ្សាយ ដើម្បីធ្វើអោយសាធារណជន និងប្រជាពលរដ្ឋមានការយល់ដឹងជ្រួតជ្រាប និងចូលរួមអនុវត្តក្នុងកិច្ចការពារបេតិកភ័ណ្ឌវប្បធម៌របស់ជាតិមាតុភូមិ និងការពារថែរក្សារមណីយដ្ឋានអង្គរ ដែលជារមណីយដ្ឋានបេតិកភ័ណ្ឌពិភពលោក ។

នៅក្នុងកិច្ចប្រជុំបច្ចេកទេសលើកទី ១៣ គណៈកម្មការអន្តរជាតិសំរបសំរួលកិច្ចគាំពារ និងអភិវឌ្ឍន៍តំបន់ប្រវត្តិសាស្ត្រអង្គរកាលពីខែកុម្ភៈ ឆ្នាំ ២០០៤ នៅទីរួមខេត្តសៀមរាប ដោយមានតំណាងប្រទេសនានា និងអង្គការអន្តរជាតិចូលរួមរាប់រយនាក់នោះ បានកោតសរសើរចំពោះរាជរដ្ឋាភិបាលកម្ពុជាយើង ក៏ដូចអាជ្ញាធរអប្សរា អាជ្ញាធរដែនដី កងកំលាំងប្រដាប់អាវុធ និងស្ថាប័នពាក់ព័ន្ធដែលបានខិតខំអនុវត្តការងារក្នុងរយៈពេលកន្លងមក ធ្វើអោយរមណីយដ្ឋានអង្គរឈានផុតពីរមណីយដ្ឋានដែលប្រឈមមុខនឹងគ្រោះថ្នាក់ ហើយក្លាយជារមណីយដ្ឋានដែលកំពុងតែអភិវឌ្ឍប្រកបដោយនិរន្តរភាព ជាពិសេសបានខិតខំអនុវត្តតាមស្មារតីសារាចរលេខ ០១ សរ ស្ដីពីការទប់ស្កាត់អំពើ អនាធិបតេយ្យនៅតំបន់សៀមរាប-អង្គរនេះ ។

ចាប់ពីពេលនេះតទៅ កាតព្វកិច្ចរបស់រាជរដ្ឋាភិបាលកម្ពុជា អង្គការយូណេស្កូ និងសហគមន៍អន្តរជាតិ ត្រូវធ្វើការរួមគ្នា ដើម្បីធានាអោយបាននូវការងារអភិរក្សរមណីយដ្ឋានអង្គរ ដោយដើរស្របគ្នាជាមួយនឹងការអភិវឌ្ឍប្រកបដោយនិរន្តរភាព សំដៅបំរើវិស័យឧស្សាហកម្មទេសចរណ៍ ដែលជាមូលដ្ឋានគ្រឹះសំខាន់ក្នុងការអភិវឌ្ឍវិស័យសេដ្ឋកិច្ច សង្គមកិច្ច និងការកាត់បន្ថយភាពក្រីក្រនៅកម្ពុជា ។

ក្នុងផ្នែកអភិរក្ស អាទិភាពត្រូវផ្ដល់អោយដល់ការថែទាំ ការពាររមណីយដ្ឋានអង្គរដែលស្ថិតនៅក្នុងតំបន់ ១ ដែលជា " រមណីយដ្ឋានមានប្រាសាទ " និងតំបន់ ២ ដែលជា " ឧទ្យានបុរាណវត្ថុត្រូវការពារ " មានទំហំប្រមាណ ៤០១គីឡូម៉ែត្រការេស្ថិតក្នុងភូមិសាស្ត្រខេត្តសៀមរាប ហើយអាចពង្រីកទំហំថែមទៀត និងមានការបែងចែកជា ៥ តំបន់ ដែលត្រូវមានកំរិតការពារលក្ខខណ្ឌប្រើប្រាស់ដីធ្លី និងការសាងសង់សំណង់ខុសៗគ្នា ។

ប៉ុន្តែទន្ទឹមនឹងមោទនភាពខាងលើ និងក្នុងរយៈពេលប៉ុន្មានខែចុងក្រោយនេះ សកម្មភាពកាប់រានដុតបំផ្លាញព្រៃឈើ ឈូសឆាយចាក់ដី ជីកយកដី ហ៊ុមព័ទ្ធរបងយកដី សាងសង់លំនៅដ្ឋានដែលមានលក្ខណៈរឹងមាំអំពីបេតុង សាងសង់សំណង់សាធារណៈរបស់រដ្ឋសំណង់សាសនា ដាក់លក់វត្ថុអនុស្សាវរីយ៍ អាហារ និងភេសជ្ជៈ ប្រេងឥន្ធនៈ ការចតយានយន្ត មធ្យោបាយដឹកភ្ញៀវទេសចរគ្មានសណ្ដាប់ធ្នាប់ និងគ្មានការអនុញ្ញាតពីសមត្ថកិច្ចនៃអាជ្ញាធរអប្សរា ព្រមទាំងការលែងគោ ក្របី ជ្រូក អោយដើរពាសវាលពាសកាលបានកើនឡើងជាបន្តបន្ទាប់ឥតឈប់ឈរនៅក្នុងតំបន់រមណីយដ្ឋានអង្គរ ខេត្តសៀមរាប ។

អំពើល្មើសទាំងនេះ បានធ្វើអោយប៉ះពាល់យ៉ាងធ្ងន់ធ្ងរដល់គោលការណ៍នីតិរដ្ឋ និងដល់គោលការណ៍អភិវឌ្ឍប្រកបដោយនិរន្តរភាព បើសិនជាវិធានការទប់ស្កាត់ និងលុបបំបាត់ ពុំត្រូវចាត់ការអនុវត្តអោយបានហ្មឹងម៉ាត់ និងមានប្រសិទ្ធភាពនោះទេ ។

ប្រការ ៤ : សមាជិកក្រុមការងារត្រូវចូលរួមប្រជុំ តាមការអញ្ជើញរបស់ប្រធាន។ ក្នុងពេលអវត្តមានប្រធានក្រុមការងារ នាយក្រុមការងារទទួលចាត់ចែងការងារជំនួស និងធ្វើរបាយការណ៍ពីលទ្ធផលការងារ ជូនប្រធានក្រុមការងារ។

ប្រការ ៥ : រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល ប្រធានអាជ្ញាធរប្រេងកាតជាតិកម្ពុជា ប្រធានអាជ្ញាធរអគ្គិសនីកម្ពុជា ប្រធាន និង សមាជិកនៃក្រុមការងារដែលមានរាយនាមក្នុងប្រការ ១ មានភារកិច្ចអនុវត្តសេចក្តីសំរេចនេះអោយមានប្រសិទ្ធិភាព ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី ២៣ ខែ មិថុនា ឆ្នាំ ២០០៤

នាយករដ្ឋមន្ត្រី

ហ៊ុន សែន

ចំលងជូន :

-ក្រសួងព្រះបរមរាជវាំង
-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
-អគ្គលេខាធិការដ្ឋានរដ្ឋសភា
-ខុទ្ទកាល័យ សម្តេចនាយករដ្ឋមន្ត្រី
-ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
-ក្រសួងពាណិជ្ជកម្ម
-ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និង សំណង់
-ក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល
-គ្រប់ក្រសួង ស្ថាប័នកណ្តាល
-គ្រប់សាលាខេត្ត ក្រុង
-ឯកសារ កាលប្បវត្តិ

ប្រការ ៤ : សមាជិកក្រុមការងារត្រូវចូលរួមប្រជុំ តាមការអញ្ជើញរបស់ប្រធាន។ ក្នុងពេលអវត្តមានប្រធានក្រុមការងារ នាយក្រុមការងារទទួលចាត់ចែងការងារជំនួស និងធ្វើរបាយការណ៍ពីលទ្ធផលការងារ ជូនប្រធានក្រុមការងារ។

ប្រការ ៥ : រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល ប្រធានអាជ្ញាធរប្រេងកាតជាតិកម្ពុជា ប្រធានអាជ្ញាធរអគ្គីសនីកម្ពុជា ប្រធាន និង សមាជិកនៃក្រុមការងារដែលមានរាយនាមក្នុងប្រការ ១ មានភារកិច្ចអនុវត្តសេចក្តីសំរេចនេះអោយមានប្រសិទ្ធិភាព ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី ២២ ខែ មិថុនា ឆ្នាំ ២០០៤

នាយករដ្ឋមន្ត្រី

ហ៊ុន សែន

<u>ចំលងជូន</u> :

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យ សម្តេចនាយករដ្ឋមន្ត្រី
- ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
- ក្រសួងពាណិជ្ជកម្ម
- ក្រសួងរៀបចំដែនដី នគររូបនីយកម្ម និង សំណង់
- ក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល
- គ្រប់ក្រសួង ស្ថាប័នកណ្តាល
- គ្រប់សាលាខេត្ត ក្រុង
- ឯកសារ កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខៈ ០៧ បប

បទបញ្ជា

ស្តីពី

ការទប់ស្កាត់ និងលុបបំបាត់អំពើអនាធិបតេយ្យ នៅតំបន់រមណីយដ្ឋានអង្គរ ខេត្តសៀមរាប

កន្លងមក រាជរដ្ឋាភិបាលបានចេញសារាចរលេខ ០១ សរ ចុះថ្ងៃទី ០៦ ខែ ឧសភា ឆ្នាំ ២០០៣ ស្តីពីការទប់ស្កាត់អំពើអនាធិបតេយ្យនៅតំបន់សៀមរាប-អង្គរ ដោយបានធ្វើការផ្សព្វផ្សាយ ដើម្បីធ្វើអោយសាធារណជន និងប្រជាពលរដ្ឋមានការយល់ដឹងជ្រួតជ្រាប និងចូលរួមអនុវត្តក្នុងកិច្ចការពារបេតិកភ័ណ្ឌវប្បធម៌របស់ជាតិមាតុភូមិ និងការពារថែរក្សារមណីយដ្ឋានអង្គរ ដែលជារមណីយដ្ឋានបេតិកភ័ណ្ឌពិភពលោក ។

នៅក្នុងកិច្ចប្រជុំបច្ចេកទេសលើកទី ១៣ គណៈកម្មការអន្តរជាតិសំរបសំរួលកិច្ចគាំពារ និងអភិវឌ្ឍន៍តំបន់ប្រវត្តិសាស្ត្រអង្គរ កាលពីខែកុម្ភៈ ឆ្នាំ ២០០៤ នៅទីរួមខេត្តសៀមរាប ដោយមានតំណាងប្រទេសនានា និងអង្គការអន្តរជាតិចូលរួមរាប់រយនាក់នោះ បានកោតសរសើរចំពោះរាជរដ្ឋាភិបាលកម្ពុជាយើង ក៏ដូចអាជ្ញាធរអប្សរា អាជ្ញាធរដែនដី កងកំលាំងប្រដាប់អាវុធ និងស្ថាប័នពាក់ព័ន្ធដែលបានខិតខំអនុវត្តការងារក្នុងរយៈពេលកន្លងមក ធ្វើអោយរមណីយដ្ឋានអង្គរឈានផុតពីរមណីយដ្ឋានដែលប្រឈមមុខនឹងគ្រោះថ្នាក់ ហើយក្លាយជារមណីយដ្ឋានដែលកំពុងតែអភិវឌ្ឍប្រកបដោយនិរន្តរភាព ជាពិសេសបានខិតខំអនុវត្តតាមស្មារតីសារាចរលេខ ០១ សរ ស្តីពីការទប់ស្កាត់អំពើ អនាធិបតេយ្យនៅតំបន់សៀមរាប-អង្គរនេះ ។

ចាប់ពីពេលនេះតទៅ កាតព្វកិច្ចរបស់រាជរដ្ឋាភិបាលកម្ពុជា អង្គការយូណេស្កូ និងសហគមន៍អន្តរជាតិ ត្រូវធ្វើការរួមគ្នា ដើម្បីធានាអោយបាននូវការងារអភិរក្សរមណីយដ្ឋានអង្គរ ដោយដើរស្របគ្នាជាមួយនឹងការអភិវឌ្ឍប្រកបដោយនិរន្តរភាព សំដៅបំរើវិស័យឧស្សាហកម្មទេសចរណ៍ ដែលជាមូលដ្ឋានគ្រឹះសំខាន់ក្នុងការអភិវឌ្ឍវិស័យសេដ្ឋកិច្ច សង្គមកិច្ច និងការកាត់បន្ថយភាពក្រីក្រនៅកម្ពុជា ។

ក្នុងផ្នែកអភិរក្ស អាទិភាពត្រូវផ្តល់អោយដល់ការថែទាំ ការពាររមណីយដ្ឋានអង្គរដែលស្ថិតនៅក្នុងតំបន់ ១ ដែលជា " រមណីយដ្ឋានមានប្រាសាទ " និងតំបន់ ២ ដែលជា " ឧទ្យានបុរាណវត្ថុត្រូវការពារ " មានទំហំប្រមាណ ៤០១គីឡូម៉ែត្រការេ ស្ថិតក្នុងភូមិសាស្ត្រខេត្តសៀមរាប ហើយអាចពង្រីកទំហំថែមទៀត និងមានការបែងចែកជា ៥ តំបន់ ដែលត្រូវមានកំរិតការពារលក្ខខណ្ឌប្រើប្រាស់ដីធ្លី និងការសាងសង់សំណង់ខុសៗគ្នា ។

ប៉ុន្តែទន្ទឹមនឹងមោទនភាពខាងលើ និងក្នុងរយៈពេលប៉ុន្មានខែចុងក្រោយនេះ សកម្មភាពកាប់រានដុតបំផ្លាញព្រៃឈើ ឈូសឆាយចាក់ដី ជីកយកដី ហ៊ុមព័ទ្ធរបងយកដី សាងសង់លំនៅដ្ឋានដែលមានលក្ខណៈរឹងមាំអំពីបេតុង សាងសង់សំណង់សាធារណៈរបស់រដ្ឋ សំណង់សាសនា ដាក់លក់វត្ថុអនុស្សាវរីយ៍ អាហារ និងភេសជ្ជៈ ប្រេងឥន្ធនៈ ការចតយានយន្ត មគ្គុទ្ទេសក៍នាំភ្ញៀវទេសចរគ្មានសណ្តាប់ធ្នាប់ និងគ្មានការអនុញ្ញាតពីសមត្ថកិច្ចនៃអាជ្ញាធរអប្សរា ព្រមទាំងការលែងគោ ក្របី ជ្រូក អោយដើរពាសវាលពាសកាល បានកើនឡើងជាបន្តបន្ទាប់ឥតឈប់ឈរនៅក្នុងតំបន់រមណីយដ្ឋានអង្គរ ខេត្តសៀមរាប ។

អំពើល្មើសទាំងនេះ បានធ្វើអោយប៉ះពាល់យ៉ាងធ្ងន់ធ្ងរដល់គោលការណ៍នីតិរដ្ឋ និងដល់គោលការណ៍អភិវឌ្ឍប្រកបដោយនិរន្តរភាព បើសិនជាវិធានការទប់ស្កាត់ និងលុបបំបាត់ ពុំត្រូវចាត់ការអនុវត្តអោយបានហ្មឹងម៉ាត់ និងមានប្រសិទ្ធភាពនោះទេ ។

ដើម្បីទប់ស្កាត់ និងលុបបំបាត់អំពើអនាធិបតេយ្យនៅតំបន់រមណីយដ្ឋានអង្គរ ខេត្តសៀមរាប រាជរដ្ឋាភិបាលបានសម្រេច ចេញនូវបទបញ្ជាបន្ទាន់ចំពោះមុខ ដូចខាងក្រោម :

១. ដោយហេតុថា តំបន់រមណីយដ្ឋានអង្គរជាបេតិកភ័ណ្ឌពិភពលោក អាជ្ញាធរអប្សរាត្រូវទទួលភារកិច្ចផ្តាច់មុខជាអ្នកអនុវត្ត ចែងពិធីគ្រប់ជំពូកទាំងអស់ក្នុងបរិវេណអង្គរ ។

អាជ្ញាធរអប្សរាជាស្ថាប័នមានសិទ្ធិផ្តាច់មុខ ក្នុងការចេញលិខិតអនុញ្ញាតសាងសង់សំរាប់ការស្ថាបនាទាំងឡាយក្នុងបរិវេណ តំបន់រមណីយដ្ឋានអង្គរ ។ ការអនុញ្ញាតសាងសង់ ដែលចេញដោយអាជ្ញាធរផ្សេងពីអាជ្ញាធរអប្សរា ទាក់ទងនឹងសំណង់នៅក្នុងតំបន់ រមណីយដ្ឋានអង្គរត្រូវចាត់ទុកជាមោឃៈ ។ សំណង់កសាងរួចហើយ ដែលគ្មានច្បាប់អនុញ្ញាតអាចត្រូវរុះរើចេញដោយម្ចាស់សំណង់ ល្មើសច្បាប់ ហើយគ្មានលក្ខខណ្ឌ ក្នុងរយៈពេល ៤៥ថ្ងៃ យ៉ាងយូរគិតពីថ្ងៃជូនដំណឹង ។

ការស្ថាបនាសំណង់សាធារណៈរបស់រដ្ឋ ដែលមានសារៈសំខាន់ចាំបាច់នៅក្នុងតំបន់ ១ និងតំបន់ ២ នៃ រមណីយដ្ឋានអង្គរ ត្រូវមានយោបល់ជាមុនលើផ្នែកបច្ចេកទេសពីអគ្គនាយកដ្ឋាននៃអាជ្ញាធរអប្សរា និងមានការយល់ព្រមពីរាជរដ្ឋាភិបាល ។

ចំពោះសំណង់សាធារណៈរបស់រដ្ឋ សំណង់សាសនា លំនៅដ្ឋានថ្មីៗ តូបលក់ដូរទំនិញគ្រប់ប្រភេទ ចំណតយានយន្ត មធ្យោបាយដឹកភ្ញៀវទេសចរ ការព័ទ្ធរបងយកដី ការដ្ឋានឈូសឆាយចាក់ដី ជីកដី ឡឥដ្ឋ ឡធ្យូង ការកាប់ឈើចម្រានយកអុស និងការចោះដើមឈើដុតយកជ័រដោយអនាធិបតេយ្យ ដែលបាន ឬកំពុងសាងសង់ និងដំណើរការនៅក្នុងតំបន់ ១ និងតំបន់ ២ នៃរមណីយដ្ឋានអង្គរ អគ្គនាយកដ្ឋាននៃអាជ្ញាធរអប្សរាត្រូវសហការជាមួយអាជ្ញាធរដែនដី និងសមត្ថកិច្ចពាក់ព័ន្ធ ដើម្បីចាត់ការអនុវត្ត ជាបន្ទាន់បំផុតនូវការចុះស្រង់ស្ថិតិឈ្មោះជនល្មើស និងទីតាំងនីមួយៗអោយបានច្បាស់លាស់ រួចកសាងសំណុំរឿងបញ្ជូនទៅតុលាការ ដើម្បីវិនិច្ឆ័យទោសតាមច្បាប់ជាធរមាន និងត្រូវធ្វើការទប់ស្កាត់មិនអោយអំពើអនាធិបតេយ្យរបៀបនេះ កើតឡើងជាថ្មីនៅតំបន់ ទាំងពីរនេះតទៅទៀតឡើយ ។

ចំពោះការដ្ឋានដែលជនល្មើសបានកាប់រានដីព្រៃឈើ ព័ទ្ធរបងយកដីនៅក្នុងរមណីយដ្ឋានអង្គរ ក្រោយពេលអនុវត្ត រឹបអូសយកមកធ្វើជាសម្បត្តិរដ្ឋតាមនីតិវិធីជាធរមានរួចហើយនោះ ត្រូវធ្វើការដាំដើមឈើឡើងវិញ និងចាត់ចែងការពារអោយបាន ហ្មឺងម៉ាត់ ។

២. រាល់ការលក់ដូរ ដោះដូរ ឬសម្បទានអ្វីមួយនៅលើដីធ្លីស្ថិតនៅក្នុងតំបន់ ១ និងតំបន់ ២ នៃរមណីយដ្ឋានអង្គរ ត្រូវចាត់ទុក ជាមោឃៈ ។ ចំពោះរាល់ការចេញលិខិត ឬប័ណ្ណសំគាល់សិទ្ធិដីធ្លីដែលស្ថិតនៅក្នុងតំបន់ទាំងពីរនេះជូនប្រជាពលរដ្ឋដែលតាំងទីលំនៅ រស់នៅយូរលង់មកហើយ ត្រូវមានយោបល់ឯកភាពពីសមត្ថកិច្ចនៃអាជ្ញាធរអប្សរាជាមុន ។

៣. រាល់វិធានការ និងការអនុញ្ញាតទាំងឡាយណាដែលចេញដោយអាជ្ញាធរជាតិ ឬអាជ្ញាធរមូលដ្ឋានគ្រប់លំដាប់ថ្នាក់ ដែល មានវិសមិតភាពជាមួយកាតព្វកិច្ចអន្តរជាតិ ដែលតម្រូវអោយព្រះរាជាណាចក្រកម្ពុជាគោរព និងអនុវត្តនៅក្នុងរមណីយដ្ឋានអង្គរ ត្រូវ ចាត់ទុកជានិរាករណ៍ ។ ហេតុនេះ ការដាក់តម្លើងអង់តែន ទូរស័ព្ទ ទូរទស្សន៍ និងសំណង់ទាំងអស់ដែលគ្មានច្បាប់កន្លងមក ហើយដែល ស្ថិតនៅក្នុងតំបន់ ១ និងតំបន់ការពារផ្សេងៗទៀត នៃរមណីយដ្ឋានអង្គរ ត្រូវតែរុះរើចេញដោយគ្មានលក្ខខណ្ឌ ហើយចាប់ពីពេលនេះ តទៅ ហាមឃាត់ដាច់ខាតការតម្លើងអង់តែន ឬសំណង់ផ្សេងៗក្នុងតំបន់១ និងតំបន់ការពារផ្សេងៗដូចខាងលើ លើកលែងតែមាន ការអនុញ្ញាតពីសមត្ថកិច្ចនៃអាជ្ញាធរអប្សរា និងមានការយល់ព្រមពីរាជរដ្ឋាភិបាល ។

៤. លើកកំពស់ការអនុវត្ត តាមគោលការណ៍នីតិរដ្ឋនៅក្នុងតំបន់រមណីយដ្ឋានអង្គរ ខេត្តសៀមរាប គឺអាជ្ញាធរអប្សរាត្រូវខិតខំ កសាងលិខិតបទដ្ឋានបន្ថែមទៀត បន្តបោះបង្គោលកំណត់ខ័ណ្ឌព្រំដីជាក់ស្តែងនៅតាមតំបន់ទាំង ៥ ការដាក់ផ្លាកសញ្ញាបង្ហាញ ការជូនដំណឹងនានាអំពីសិទ្ធិប្រើប្រាស់ដីធ្លី និងកំរិតលក្ខខណ្ឌនៃការសាងសង់សំណង់ ហើយធ្វើការផ្សព្វផ្សាយជាប់ជាប្រចាំ និងកៀរគរ ស្មារតីចូលរួមអនុវត្តច្បាប់ បទបញ្ជា បទប្បញ្ញត្តិ និងលិខិតបទដ្ឋាន ដែលពាក់ព័ន្ធជាមួយនឹងតំបន់រមណីយដ្ឋានអង្គរ កិច្ចការពារ បេតិកភ័ណ្ឌវប្បធម៌ ការការពារព្រៃឈើ និងសត្វព្រៃជាដើម ជូនកងកំលាំងប្រដាប់អាវុធ មន្ត្រីរាជការ សិស្សានុសិស្ស ព្រះសង្ឃ សាធារណជន និងប្រជាពលរដ្ឋគ្រប់មូលដ្ឋាន ដោយសហការជាមួយអាជ្ញាធរដែនដីគ្រប់លំដាប់ថ្នាក់ គ្រឹះស្ថានសិក្សា វត្តអារាម ភ្នាក់ងារ និងអង្គភាពមានសមត្ថកិច្ចពាក់ព័ន្ធ ។ *Ru*

៥. អគ្គនាយកដ្ឋាននៃអាជ្ញាធរអប្សរា ត្រូវខិតខំជំរុញដំណើរការរៀបចំ អោយមានសណ្តាប់ធ្នាប់របៀបរៀបរយ ធានារក្សានូវសោភ័ណភាពប្រាសាទបុរាណសំរាប់បំរើការទស្សនារបស់ភ្ញៀវទេសចរជាតិ និងអន្តរជាតិ នៅក្នុងតំបន់ ១ និងតំបន់ ២ នៃរមណីយដ្ឋានអង្គរនូវតូបលក់វត្ថុអនុស្សាវរីយ៍ អាហារ និងភេសជ្ជៈ ផ្លូវថ្មើរជើង ចំណតយានយន្ត និងមធ្យោបាយដឹកជញ្ជូនភ្ញៀវ ទេសចរ ដោយហាមឃាត់ដាច់ខាតមិនអោយមានការលក់ដូរប្រេងឥន្ធនៈ និងគ្រឿងឆេះផ្សេងៗ ព្រមទាំងមិនអោយលែងគោ ក្របី ជ្រូក ពាសវាលពាសកាលឡើយ ។

៦. គ្មានរូបវន្តបុគ្គល នីតិបុគ្គល សមាគម អង្គការ ឬអាជ្ញាធរណាមួយមានសិទ្ធិផ្តល់ការអនុញ្ញាត ទោះដោយផ្ទាល់ក្តី ដោយប្រយោលក្តី អោយកាប់រានដី ដុតឈូសឆាយព្រៃឈើ ចាក់ដី ជីកដី បង្កើតឡឥដ្ឋ ឡធ្យូង ហ៊ុមព័ទ្ធរបងយកដី សាងសង់សំណង់សាធារណៈរបស់រដ្ឋ សំណង់សាសនា លំនៅដ្ឋាន តូបលក់ដូរទំនិញគ្រប់ប្រភេទ ឬការចាត់ចែងរៀបចំចំណតយានយន្ត និងមធ្យោបាយដឹកជញ្ជូនភ្ញៀវទេសចរនៅក្នុងតំបន់ ១ និងតំបន់ ២ នៃរមណីយដ្ឋានអង្គរ ក្រៅពីសមត្ថកិច្ចរបស់អគ្គនាយកដ្ឋាន នៃអាជ្ញាធរអប្សរាឡើយ ។

អគ្គនាយកដ្ឋាននៃអាជ្ញាធរអប្សរា ត្រូវរៀបចំទីស្នាក់ការធ្វើការរួមមួយជាបន្ទាន់ ដែលម្យ៉ាងសំរាប់អោយថ្នាក់ដឹកនាំអគ្គនាយកដ្ឋាននៃអាជ្ញាធរអប្សរា និងមន្ត្រីរាជការ បុគ្គលិកបំរើការងារផង និងម្យ៉ាងទៀត ដើម្បីបង្កលក្ខណៈងាយស្រួលដល់ វិនិយោគិន សាធារណជន ប្រជាពលរដ្ឋ ស្ថាប័ន អង្គភាពមានសមត្ថកិច្ច អង្គការក្រៅរដ្ឋាភិបាលជាតិ និងអន្តរជាតិ និងតំណាងប្រទេសនានា ធ្វើការទាក់ទងការងារ ព្រមទាំងត្រូវកំណត់អំពីនីតិវិធីនៃការផ្តល់លិខិតអនុញ្ញាតតាមច្រកចេញ ចូលតែមួយ រយៈពេលនៃការដាក់ពាក្យស្នើសុំរុះរើ កែលំអ សាងសង់លំនៅដ្ឋាន ការវិនិយោគ និងកិច្ចការទំនាក់ទំនងសាធារណៈផ្សេងៗទៀតជាដើម ដែលពាក់ព័ន្ធនឹងការងារអភិរក្ស និងអភិវឌ្ឍនៅក្នុងតំបន់រមណីយដ្ឋានអង្គរ ។

៧. ជនណាដែលប្រព្រឹត្តផ្ទុយនឹងបទបញ្ជាខាងលើនេះ ត្រូវទទួលខុសត្រូវចំពោះមុខច្បាប់ ស្តីពីកិច្ចការពារបេតិកភ័ណ្ឌវប្បធម៌ ច្បាប់ស្តីពីព្រៃឈើ ច្បាប់ភូមិបាល ច្បាប់ និងលិខិតបទដ្ឋានជាធរមាន ។

៨. ទទួលបាននូវបទបញ្ជានេះ គ្រប់ក្រសួង ស្ថាប័នពាក់ព័ន្ធ អគ្គបញ្ជាការដ្ឋានកងយោធពលខេមរភូមិន្ទ អគ្គស្នងការដ្ឋាននគរបាលជាតិ បញ្ជាការដ្ឋានកងរាជអាវុធហត្ថលើផ្ទៃប្រទេស អគ្គនាយកដ្ឋាននៃអាជ្ញាធរអប្សរា និងអាជ្ញាធរដែនដីគ្រប់លំដាប់ថ្នាក់នៃខេត្តសៀមរាប និងខេត្ត ក្រុងពាក់ព័ន្ធ ត្រូវផ្សព្វផ្សាយអោយបានទូលំទូលាយ និងចាត់ចែងអនុវត្តអោយមានប្រសិទ្ធភាព ដោយទទួលលទ្ធផលវិជ្ជមាន ។ Ru

រាជធានីភ្នំពេញ ថ្ងៃទី ២៣ ខែ មិថុនា ឆ្នាំ ២០០៤

នាយករដ្ឋមន្ត្រី

ហ៊ុន សែន

<u>កន្លែងទទួល</u>

-ក្រសួងព្រះបរមរាជវាំង
-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
-អគ្គលេខាធិការដ្ឋានរដ្ឋសភា
-ក្រសួង ស្ថាប័ន រដ្ឋលេខាធិការដ្ឋាន
-អគ្គលេខាធិការរាជរដ្ឋាភិបាល
-ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
-ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី
-សាលាខេត្ត-ក្រុង
-ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសាធារណការ និង ដឹកជញ្ជូន

ក្រសួងអភិវឌ្ឍន៍ជនបទ

លេខ:...2821............បក.សក ករអ

ប្រកាសអន្តរក្រសួង
ស្តីពី
ការកំរិតកំណត់ទំងន់ អតិបរមា នៃរថយន្តដឹកជញ្ជូន ផ្លូវគោក ដែលបើកបរលើបណ្តាញផ្លូវខេត្ត និង ផ្លូវជនបទ នៃព្រះរាជាណាចក្រកម្ពុជា

រដ្ឋមន្ត្រីក្រសួងសាធារណការ និង ដឹកជញ្ជូន
និង រដ្ឋមន្ត្រីក្រសួងអភិវឌ្ឍន៍ជនបទ

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា ។

- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែវិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា ។

- បានឃើញព្រះរាជក្រមលេខ ០២ / នស / ៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី ។

- បានឃើញព្រះរាជក្រម នស/រកម/០១៩៦/០៣ ចុះថ្ងៃទី២៤ខែមករាឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការបង្កើតក្រសួងសាធារណការ និង ដឹកជញ្ជូន ។

- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១២ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការបង្កើតក្រសួងអភិវឌ្ឍន៍ជនបទ។

- បានឃើញព្រះរាជក្រឹត្យលេខ ៦៨ក្រ ចុះថ្ងៃទី៣១ ខែសីហា ឆ្នាំ ១៩៩១ ដែលប្រកាសអោយប្រើច្បាប់ស្តីពី ចរាចរផ្លូវគោក ។

- បានឃើញអនុក្រឹត្យលេខ ១៤ អនក្រ-បក ចុះថ្ងៃទី០៣ ខែមិនា ឆ្នាំ១៩៩៨ ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅរបស់ក្រសួងសាធារណការ និង ដឹកជញ្ជូន ។

- បានឃើញអនុក្រឹត្យលេខ ២០ អនក្រ / បក / ចុះថ្ងៃទី៣០ ខែមេសា ឆ្នាំ១៩៩៦ ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅរបស់ក្រសួង និង រដ្ឋលេខាធិការដ្ឋាន។

- បានឃើញអនុក្រឹត្យលេខ ៧៨ អនក្រ / បក ចុះថ្ងៃទី ០១ ខែ ធ្នូ ឆ្នាំ១៩៩៧ ស្ដីពីការរៀបចំ និង ការប្រព្រឹត្តិទៅរបស់ក្រសួងអភិវឌ្ឍន៍ជនបទ ។

- បានឃើញអនុក្រឹត្យលេខ៩១ អនក្រ/បក ចុះថ្ងៃទី ២១ ខែ មិថុនា ឆ្នាំ២០០១ ស្ដីពីការធ្វើវិសោធនកម្មលើអនុក្រឹត្យលេខ៧៨ អនក្រ/បក ចុះថ្ងៃទី០១ ខែ ធ្នូ ឆ្នាំ១៩៩៧ ស្ដីពីការរៀបចំ និង ការប្រព្រឹត្តិទៅរបស់ក្រសួងអភិវឌ្ឍន៍ជនបទ ។

- ដោយបានការឯកភាពពីគណៈរដ្ឋមន្ត្រី នាសម័យប្រជុំពេញអង្គថ្ងៃទី ០៣ ខែ កញ្ញា ឆ្នាំ ១៩៩៩ ។

- យោងតាមអនុសាសន៍របស់សម្ដេចនាយករដ្ឋមន្ត្រីចុះថ្ងៃទី ២៩ ខែ មិនា ឆ្នាំ ២០០៤ ក្នុងឱកាសសម្ពោធបើកការដ្ឋានសាងសង់ស្ពានដើមស្ដៅ ស្រុកកោះសូទិន ខេត្តកំពង់ចាម ។

សំរេច

ប្រការ១ :

ប្រកាសនេះ មានគោលបំណងកំណត់ការគ្រប់គ្រងទម្ងន់រថយន្តដឹកជញ្ជូនទំនិញតាមបណ្ដាញផ្លូវខេត្ត និង ផ្លូវជនបទទាំងអស់ក្នុងព្រះរាជាណាចក្រកម្ពុជា សំដៅធានាភាពស្ថិតស្ថេរ របស់ផ្លូវថ្នល់ឱ្យបានយូរអង្វែងស្របតាមបច្ចេកទេស នៃការស្ថាបនាផ្លូវថ្នល់ ។

ប្រការ២ :

និយមន័យ

ក. **ត្រូវបានហៅថា :**

- រថយន្តដឹកជញ្ជូន : សំដៅរថយន្តដែលមានម៉ាស៊ីនភ្ជាប់ជាមួយភ្លៅរថយន្ត គឺអ័ក្សរបស់រថយន្ត ដែលភ្ជាប់ដោយកង់រថយន្តខាងឆ្វេង និង ខាងស្ដាំ ។ កង់នោះអាចជាកង់សាមញ្ញ ឬ កង់ភ្លោះ ។
- ភ្លៅទោល : គឺជាភ្លៅរថយន្ត ដែលមានចំងាយយ៉ាងតិច ១,៨០ម៉ែត្រ ពីភ្លៅមួយទៀត ។
- ភ្លៅឌុប : សំដៅភ្លៅរថយន្តពីរ នៅចំងាយពីគ្នាតិចជាង ១,៨០ម៉ែត្រ និង ឆ្ងាយជាង ១,៣០ម៉ែត្រ

ខ. **ផ្លូវខេត្ត :**

១. ផ្លូវខេត្តជាផ្លូវដែលចេញពីខេត្ត ឆ្ពោះទៅកាន់ទីរួមស្រុក

២. ផ្លូវបំបែកចេញពីផ្លូវជាតិ ឆ្ពោះទៅទីរួមខេត្ត

៣. ផ្លូវបំបែកពីផ្លូវខេត្តឆ្ពោះទៅស្រុកក្នុងករណីចំនួនចរាចរមធ្យមប្រចាំថ្ងៃ (ADT) លើសពី ៥០ ។

៤. ផ្លូវបែកចេញពីផ្លូវខេត្តឆ្ពោះទៅផ្លូវខេត្ត ។

៥. ផ្លូវជនបទក្នុងករណីចំនួនចរាចររថយន្តមធ្យមប្រចាំថ្ងៃ (ADT) ធំជាង ៥០ ។

៦. ផ្លូវផ្សេងៗទៀតតាមការកំណត់របស់ក្រសួងសាធារណការ និង ដឹកជញ្ជូន ។

- **ប្រភេទលេខផ្លូវខេត្ត :**

ផ្លូវខេត្តមានលេខ៣ខ្ទង់ លេខ៤ខ្ទង់ និង លេខ២ខ្ទង់និងអក្សរតាងឈ្មោះខេត្តនៅកណ្ដាល

គ. **ផ្លូវជនបទ :**

១ – ផ្លូវដែលចេញពីផ្លូវជាតិឆ្ពោះទៅឃុំ - ភូមិ

២ – ផ្លូវដែលចេញពីផ្លូវខេត្តឆ្ពោះទៅ ឃុំ - ភូមិ

៣– ផ្លូវដែលចេញពីទីរួមស្រុក ទៅ ទីរួមស្រុក

៤ – ផ្លូវចេញពីទីរួមស្រុកទៅឃុំ

៥ – ផ្លូវចេញពីឃុំ ទៅ ឃុំ

៦ – ផ្លូវចេញពីឃុំ ទៅ ភូមិ

៧ – ផ្លូវបែកពីភូមិ ទៅ ភូមិ

៨ – ផ្លូវជនបទ ទៅ ផ្លូវផ្សេងទៀត

- ក្រុមបណ្ដាញផ្លូវខេត្ត : តាមប្រកាសរបស់ក្រសួងសាធារណការ និង ដឹកជញ្ជូន ។ (ដូចមានចែងក្នុងឧបសម្ព័ន្ធ ១)
- ក្រុមបណ្ដាញផ្លូវជនបទ : តាមប្រកាសរបស់ក្រសួងអភិវឌ្ឍន៍ជនបទ ។

ប្រការ៣ :

ទំងន់រថយន្តដឹកជញ្ជូន ដែលធ្វើចរាចរតាមក្រុមបណ្ដាញផ្លូវខេត្ត ដូចបានចែងខាងលើត្រូវបានកំណត់អតិបរមាដូចតទៅ :

១-ចំពោះរថយន្តដឹកជញ្ជូនដែលមានភ្លៅ២គិតទំងន់ជាអតិបរមាអនុញ្ញាតិគឺ ១៦តោន ។

២-ចំពោះរថយន្តដឹកជញ្ជូនដែលមានភ្លៅ៣គិតទំងន់ជាអតិបរមាអនុញ្ញាតិគឺ ២០តោន ។

(ដូចបានចែងក្នុងតារាងឧបសម្ព័ន្ធទី២) ។

ប្រការ៤ :

ទំងន់រថយន្តដឹកជញ្ជូន ដែលធ្វើចរាចរតាមក្រុមបណ្ដាញផ្លូវជនបទ ដូចបានចែងខាងលើ ត្រូវបានកំណត់ជាអតិបរមាដូចតទៅ :

- ចំពោះរថយន្តយន្តដឹកជញ្ជូនដែលមានភ្លៅ ២ គិតទំងន់ជាអតិបរមាអនុញ្ញាតិ គឺ៦តោន ។

ប្រការ៥ :

- **ផ្លូវខេត្ត :**

មិនអនុញ្ញាតិអោយរថយន្តសណ្ដោង រថយន្តដឹកកុងតឺន័រ រថយន្តកែច្នៃធ្វើចរាចរ ។ ក្នុងករណីមានការដឹកជញ្ជូនពិសេស ដែលមានទំងន់លើសពីកំរិតទំងន់ដែលបានចែងក្នុងប្រកាសនេះ ហើយ ដែលមានលក្ខណៈចាំបាច់ និងប្រព្រឹត្តិឡើងម្ដងម្កាល ម្ចាស់រថយន្តត្រូវធ្វើពាក្យសុំអនុញ្ញាតិមក នាយកដ្ឋានផ្លូវថ្នល់ មន្ទីរសាធារណការ និង

ដឹកជញ្ជូន (ភ្ជាប់ជាមួយតារាងប្រភេទរថយន្តដឹកជញ្ជូន) ដើម្បីពិនិត្យ និងសំរេច តែត្រូវធ្វើការជួសជុលថែទាំផ្លូវថ្នល់-ស្ពានប្រសិនបើមានការខូចខាតពេលដឹកជញ្ជូនបានបញ្ចប់។

- ផ្លូវជនបទ :

មិនអនុញ្ញាតិអោយ រថយន្តសណ្តោង រថយន្តដឹកកុងតឺន័រ រថយន្តកែច្នៃ និង រថយន្តមានភ្លៅបីធ្វើចរាចរ។ ក្នុងករណីមានការដឹកជញ្ជូនពិសេស ដែលមានទំងន់លើសពីកំរិតទំងន់ដែលបានចែងក្នុងប្រកាសនេះ ហើយដែលមានលក្ខណៈចាំបាច់ និងប្រព្រឹត្តិឡើងម្តងម្កាលម្ចាស់រថយន្តត្រូវធ្វើពាក្យសុំអនុញ្ញាតិមក នាយកដ្ឋានផ្លូវលំ មន្ទីរអភិវឌ្ឍន៍ជនបទ (ភ្ជាប់ជាមួយតារាងប្រភេទរថយន្ត ដឹកជញ្ជូន) ដើម្បីពិនិត្យ និងសំរេច តែត្រូវធ្វើការជួសជុលថែទាំផ្លូវថ្នល់-ស្ពានប្រសិនបើមានការខូចខាតពេលដឹកជញ្ជូន បានបញ្ចប់។

ប្រការ៦ :

-កំរិតកំណត់ទំងន់អនុញ្ញាតិឆ្លងកាត់ស្ពានដែលសរសេរលើផ្លាកសញ្ញាចរាចរ គឺជាទំងន់អនុញ្ញាតិនៃរថយន្តដឹកជញ្ជូន។

